ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ១០ (ខែមករា ឆ្នាំ២០២០)

សាលដីកានេះអាចរកបាននូវ៖[សាលដីកាតុ.កំពូលលេខ ១០ (ឆបោក)]

**ពាក្យគន្លឹះ៖** ឆបោក, ជាតុផ្សំបទល្មើស, កិច្ចសន្យាលក់ទិញដី

## ១. អង្គហេតុនិងខ្លឹមសារសម្រេច

ក្នុងឆ្នាំ២០១១ ជនជាប់ចោទពីររូបបានទិញដីតម្លៃជិត២មឺនដុល្លា។ ជនរងគ្រោះបានទទួលលុយជាង១មឺន និងផ្ទេរវិញ្ញាបនបត្រសម្គាល់អចលនៈវត្ថុដាក់ឈ្មោះជនជាប់ចោទ។ ឆ្នាំ២០១២ ដល់កំណត់សង លុយថ្លៃដីបង្គ្រប់ ពួកគេមិនបានសង ហើយបានខ្ចីបណ្ណកម្មសិទ្ធិទៅបញ្ចាំនៅធនាគារ។ ទោះបីជាយ៉ាងនេះក្តី ពួកមិនបានសងប្រាក់បង្គ្រប់ទេ។

អង្គហេតុនេះត្រូវបានចោទជាបទឆបោក តាមមាត្រា៣៧៧និង៣៧៨ នៃក្រមព្រហ្មទណ្ឌ។ សាលាដំបូងរាជធានីភ្នំពេញតាមសាលក្រមលេខ២១២៥ ខែសីហា ឆ្នាំ២០១៧ សម្រេចឲ្យរួចផុតពីបទចោទម្នាក់និងសម្រេចដាក់ទោសជនជាប់ចោទម្នាក់ទៀត១ឆ្នាំ តែព្យួរធម្មតា និងបង្គាប់ឲ្យសងការខូចខាតប្រហែល៥ពាន់ដុល្លា ព្រមទាំងជំងឺចិត្ត១០លានរៀល។ សាលាឧទ្ធរណ៍ចេញសាលដីកាលេខ៤៨ ខែតុលា ឆ្នាំ២០១៨ បដិសេធសាលក្រមនិងសម្រេចរួចផុតពីបទចោទប្រកាន់។ ឯកឧត្តមអគ្គព្រះរាជអាជ្ញាបានប្តឹងសាទុក្ខ។

## តុលាការកំពូល

អគ្គព្រះរាជអាជ្ញាបានអះអាងថា ជនជាប់ចោទមានឧបាយកលទុច្ចរិត លួងលោមខ្ចីប្លង់ដី ...នេះជាបទឆបោក។ មេធាវីជនរងគ្រោះថ្លែងថា ការសម្រេចឲ្យរួចខ្លួន ដោយផ្អែកថាវាជារឿង មិនគោរពកិច្ចសន្យាជាការមិនត្រឹមត្រូវទេ។

....

៥. យល់ឃើញថា*....ដំបូងជារឿងកិច្ចសន្យា តែក្រោយមកប្រើល្បិចយកបានប្លង់ដី តែមិនយកប្រាក់មកសង...គេចវេស និងបាត់ដំណឹង...។ អំពើដែលជនជាប់ចោទបានប្រព្រឹត្តដោយប្រើល្បិចកលទុច្ចរិត ដើម្បីទទួលបានបណ្ណសម្គាល់ម្ចាស់អចលនៈវត្ថុពីដើមបណ្តឹងរដ្ឋប្បវេណីដែលជាភាគីលក់ ហើយបានធ្វើឲ្យខូចប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីដោយអំពើប្រើល្បិចកលទុច្ចរិតនេះហើយ គឺជាធាតុបានជាបទល្មើសឆបោក..*

## សម្រេច

**២.** បដិសេធសាលដីកាលេខ៤៨...**៣.** បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១៤ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ទៅសាលាឧទ្ធរណ៍...ដើម្បីធ្វើការជំនុំជម្រះជាថ្មីឡើងវិញ។...

## ២. កំណត់សំគាល់

**ក.** ចាប់ពីថ្ងៃកើតហេតុមកដល់សវនាការនៅតុលាការកំពូល មានរយៈពេល៩ឆ្នាំ។

**ខ.** តាមខ្លឹមសារនៃសាលដីកា បទឆបោកហួសពីការគ្រាន់តែរឿងបំពានកិច្ចសន្យា។ វាទាមទារនូវឧបាយកលទុច្ចរិត ទទួលបានអ្វីមួយ ក្រៅសកម្មភាពកិច្ចសន្យា នាំឲ្យជនរងគ្រោះខូចប្រយោជន៍។ តុលាការកំពូលបានជួយបំភ្លឺធាតុផ្សំនៃបទឆបោក។